# ការសំភាសន៍របស់អ្នកមីង ប្រាក់ ថារី

កៈ អ្នកដែលសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ ប្រាក់ ថារី

## <u>ការសង្ខេបរបស់អ្នកមីង ប្រាក់ ថារី</u>

នៅក្នុងនេះអ្នកមីងប្រាក់ ថារី បានរៀបរាប់អំពីជីវិតរបស់អ្នកមីងនឹងអនុស្សាវរិយ៍ខ្លះៗជាមួយបងប្អូន ហើយអ្នកមីងបានកើតទាន់របបសង្គ្រាមប៉ុលពតដែរប៉ុន្តែគាត់នៅរៀងក្មេងដែរ ហើយគាត់ពុំសូវរងនូវការលំបាកច្រើនដូចប្រជាជនឯទៀតទេ គាត់ពិតជាមានសំណាងគាត់បានហូបគ្រប់គ្រាន់ដែរ តែម្តាយគាត់បានធ្វើការច្រើនហើយលំបាក នៅពេលបែកសង្គ្រាមគឺគាត់ត្រូវបានខ្ចាត់ខ្ចាយបងប្អូនតែត្រូវបានរកគ្នាឃើញវិញ។ អ្នកមីងបានរៀបការជាមួយស្វាមីតែបានកូន៥នាក់ប្តីគាត់បានមានស្រីហើយលែងខ្វល់នឹងគាត់ អ្នកមីងត្រូវរកស៊ីយ៉ាងលំបាកក្នុងការចិញ្ចឹមកូនតែមកដល់ឥឡូវនៅពេលកូនធំៗគាត់មានជីវភាពគ្រាន់បើហើយកនបានថែទាំបាយទឹកអីអោយគាត់វិញ ឥឡូវគាត់រស់នៅដោយរីករាយ។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវិតរបស់អ្នកមីងនៅក្នុងថ្ងៃដែលយើងសំភាសន៍គឺនៅក្នុងឆ្នាំ២០១៨នៅខែមករា ហើយការសំភាសន៍នេះមានទីតាំងស្ថិតនៅក្នុងភូមិបឹងត្របែក សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា។អ៊ីចឹងអ្នកមីងញ៉ុមនឹងចាប់ផ្តើមសំភាសន៍អ្នកមីងតែម្តង តើអ្នកមីងឈ្មោះពេញឈ្មោះអីគេដែរអ្នកមីង?

ខៈញ៉ុមឈ្មោះថារីអ៊ីចឹងម៉ង!!

កៈត្រកូលអីគេដែរអ្នកមីង?

ខះត្រកូលប្រាក់ថារី។

កះឈ្មោះពិរោះណាស់អ្នកមីង                    មានចៅស្តេចមួយឈ្មោះថារីហ្នឹងដែរតើអ្នកមីង!!ចាំអ៊ិចឹងអ្នកមីអសំរាប់ឆ្នាំនេះអ្នកមីងអាយុប៉ុន្មានហើយអ្នកមីង??

ខះអាយុ៥៦ហើយអូន។

កះចាំ!!អ៊ីចឹងអ្នកមីងកើតតាំងពីឆ្នាំប៉ុន្មានដែរបានអាយុ៥៦ឆ្នាំ?

ខះមិនដឹងប៉ុន្មានទេមីអូនអើយ!!អត់ដឹងឆ្នាំប៉ុន្មានផង។

កះអត់ដឹងឆ្នាំណាទេហោ??

ខះអត់ចាំដែរ។

កះចាំគ្រាន់តែដឹងថាឆ្នាំ២០១៨អ្នកមីងអាយុ៥៦ឆ្នាំ??

ខះចាំ!!គ្រាន់តែដឹងអ៊ីចឹងឆ្នាំអារឿងបារាំងអ៊ីអត់ចេះអត់ដឹងទេអូន!!

កះហើយចុះឆ្នាំខ្មែរ?

ខះឆ្នាំខ្មែរកើតឆ្នាំម្សាញ់អូន។

កះចាំ!អ្នកមីងកើតនៅក្នុងភូមិឃុំអីគេដែរ?

ខះឃុំឈូកសរហោាឃុំឈើទាល ភូមិឈូកសរអូន!!

កះចាំអាហ្នឹងគេហៅខេត្តអីគេអ្នកមីង?

ខះខេត្តស្វាយរៀងស្រុកស្វាយជ្រំ។

កះហ្វា!!អ៊ីចឹងអ្នកមីងសំរាប់អើរអ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរអ្នកមីង?

ខះបងប្អូនញ៉ុមច្រើនណាស់កូនអើរ ១០ហ្វា!!

កះអូយ!ច្រើន!!ខះចាំ!!កះអ៊ីចឹងអ្នកមីងអើរមានបងប្អូនប្រុសស្រីហ្នឹងស្រីប៉ុន្មានប្រុសប៉ុន្មានដែរមីង?

ខ៖ប្រុស៩ស្រី៦អូន។

ក៖ចាំ!!ហើយអ្នកមីងជាកូនទីប៉ុន្មានវិញ?

ខ៖ញុំមជាកូនទី៧ហើយ។

ក៖កូនទៅ៧ហើយ។អ្នកមីងចាំឈ្មោះរបស់ពួកគាត់ទាំងអស់ទេ តាំងពីបងគេរហូតដល់ពៅគេ?

ខ៖ចាំតើអូន!!

ក៖អ្នកមីងអាចរៀបរាប់ប្រាប់មក។

ខ៖អើរបងគេធំគី!!ក៖ចាំ!!ខ៖មកធំកុល។

ក៖តែត្រកូលប្រាក់ទាំងអស់មីងណោះ?

ខ៖ចាំចាំ!!

ក៖ហើយអីគេទៀតមីង?

ខ៖ធំកុលហើយអើរធំវ៉ាត !!

ក៖ចាំ!!

ខ៖វ៉ាតហើយធំដាន អំដានហើយធំញាន ធំញានហើយធំខន ធំខនហើយធា មកប្អូនញុំមអ៊ីលី ចាន់លី។

ក៖ចាំ!!ចាន់ថាច ប៉ុណ្ណឹងអូន តែប៉ុណ្ណឹងនាក់ អ៊ីចឹងឈ្មោះចាន់ថាចហ្នឹងពៅគេហេ?

ខ៖ពៅគេតើអូន។

ក៖អ្នកមីងធ្លាប់មានអនុស្សាវរីយ៍អីគេខ្លះជាមួយបងប្អូនដែរអ្នកមីង?

ខ៖ហើរមានអីទេអូនអើយមានតែល្វីតជូរចត់អីកាលជំនាន់អាពតហាំអូន!!

ក៖អ្នកមីងរៀបរាប់ខ្លះៗមក!!

ខ៖ដល់ឥឡូវមានអីទេបងប្អូនធម្មតា។

ក៖ចាំ!!អ្នកមីងភាគច្រើនលេងអីគេខ្លះជាមួយពួកគាត់ដែរ?

ខ៖មិនដែលលេងអីផង។

ក៖នៅពីក្មេងមានលេងប៉ៃឡុកប៉ៃឡអីជាមួយគ្នាទេ?

ខ៖ធ្លាប់លេងដែរ ធ្លាប់ទៅមើលគោទៅមើលអីអូន!!

ក៖ទាំងក្រុមៗអ៊ីចឹងទៅ។

ខ៖ចាំ!!បងប្អូនទៅមិនដែលនៅលេងផ្តេសផ្តាសនៅផ្ទះទេ មានតែទៅវាល ទៅធ្វើស្រែហ្នឹង។

ក៖ចាំ!!

ខ៖ធ្វើការកសិករហ្នឹង កាលហ្នឹងមានដែលនេះអី!!

ក៖ព្យួរស្រែព្យួរអីអ៊ីចឹងទៅមីងណោះ??

ខ៖ចាំ!!ហ្នឹងហើយ អត់ដែលនៅផ្ទះដើរលេងអីទេ!!

ក៖ភាគច្រើនអ្នកមីងរបរនៅខេត្តស្វាយរៀងហ្នឹងគេធ្វើអីគេដែរមីង?

ខ៖ធ្វើតែស្រែហ្នឹងអូនខ្លះគេរកលក់ដូរអីទៅ ។

ក៖ចាំ!!ហើយអើរអ្នកមីងសំរាប់ឪពុកម្តាយអ្នកមីងគាត់រកស៊ីអីគេដែរដើម្បីចិញ្ចឹមអ្នកមីងទាំងអស់?

ខ៖អត់ រក!

ក៖តែស្រែចំការហ្នឹងទេហ៎??

ខ៖តែស្រែចំការហ្នឹងម៉ាក់ញុំរកប៉ាញុំ!!

ក៖ចាំ!!

ខះឪពុកខ្ញុំគណៈកម្មាធិការវត្ត អាចារ្យវត្ត។

កះហ្ហ៎!!អាចារ្យវត្ត??

ខះចា៎!!ម៉ែញ៉ុមធ្វើការម៉ាក់ញ៉ុមធ្វើការ។

កះចា៎!!ហើយមានដីច្រើនធ្វើស្រែទេមីង?

ខះដីតិចហ្នឹងអូន កាលពីកាលពីជំនាន់ពីដើមដីច្រើនដល់ពេលបែកអាពតហើយគ្មានដីទេ។

កះចា៎!!!

ខះគេចែកអោយតែបានប៉ុន្មានហិចតា ប៉ុន្តែគាត់ចែកកូនៗអស់ដែរហ្នឹង។

កះហើយអ៊ីចឹងអ្នកមីងសំរាប់បងប្អូនអ្នកមីងឥលូវគាត់នៅរស់ទាំងអស់គ្នាឬក៏មានអ្នកខ្លះស្លាប់ហើយ?

ខះស្លាប់មួយអូន។

កះគាត់ស្លាប់មូលហេតុអីគេដែរមីង?

ខះស្លាប់ឈឺក្តៅ
ក្តៅរងាហ្អែងគាត់ក្តៅអន្ទះអន្ទែងអូន!!មិនដឹងគាត់ចេញរោគអីសញ្ញាអីអត់ដឹងដែរ ។

កះចា៎!!

ខះឈឺតែមួយអាទិត្យហ្នឹងស្លាប់នៅក្មេងបងញ៉ុមហ្នឹង!!

កះចា៎!!បងគេបង្អស់ឬក៏ម៉េចដែរមីង?

ខះបងគេបង្អស់។

កះចា៎!!ហើយចុះឥឡូវអ្នកមីងអ្នកដែលនៅសល់រស់នៅហ្នឹងគាត់នៅឯណាខ្លះទៅ?

ខះនៅស្រុកទាំងអស់អូន។

កះនៅស្រុកស្វាយរៀងទាំងអស់?

ខះចាំ!!អត់ដែលមានបានមករកស៊ីទេ ប្អូនញ៉ុមធ្វើតែស្រែអី រកមុខរបរអីតិចតួចនៅផ្ទះហា៎!!

កះចាំ!!

ខះមកតែខ្ញុំកូន កូនមកតាមកូនៗហ្នឹង ។

កះហ៊ឺៗ!!អ៊ីចឹងរាល់ថ្ងៃអ្នកមីងនៅផ្ទះនេះជាមួយអ្នកណាគេខ្លះដែរ?

ខះនៅជាមួយកូនពៅញ៉ុមនោះឥឡូវទៅលក់បាត់ហើយ!!ម៉ាក់មីទូចមិញនោះ!!

កះគាត់លក់អីគេវិញអ្នកមីង?

ខះលក់ភេសជ្ជៈទឹកអំពៅទឹកអីគ្រឿងម្ហូរអីអូន សព្វមុខហ្នឹង។

កះហ៊ឺៗ!!អ្នកមីងមានអនុស្សាវរីយ៍អីគេខ្លះដែលចងចាំជាមួយបងប្អូនអីខ្លាំងជាងគេអីអត់??

ខះហ៊ឺគ្មានអីទេអូននៅបែកគ្នាទាំងអស់។

កះហើយបងប្អូនទាំងអស់ស្រលាញ់អ្នកណាជាងគេអីអត់??

ខះស្រលាញ់ស្មើគ្នា មិនស្រលាញ់អ្នកណាខ្លាំងជាងអ្នកណាទេ!!!

កះចាំ!!អ៊ីចឹងអ្នកមីងសំរាប់ឪពុកអ្នកមីងគាត់ឈ្មោះអីគេដែរអ្នកមីង?

ខះឈ្មោះប្រាក់ កែវ។

កះចាំ!!!ឥលូវគាត់នៅរស់?

ខះអត់ទេ គាត់ស្លាប់យូរហើយអូន។តាំងពី!!!

កះគាត់ស្លាប់មូលហេតុអីដែរ?

ខះគាត់ចាស់!!ជំងឺចាស់អូន។

កះចាំ!!!

ខះគាត់អាយុ៨០ ៩០ ជាងហើយហ្នឹងស្លាប់។

កះហើយគាត់ស្លាប់ប៉ុន្មានឆ្នាំហើយអ្នកមីងចាំទេ?

ខះ ស្លាប់តាំងពី៨៣ណោះ(១៩៨៣)ស្លាប់យូរហើយ ។

កះហើយពេលគាត់ស្លាប់ហ្នឹង៩០ជាងហើយហេ៎??

ខះ៩០ជាងហើយអូន!!

កះ៩០ប៉ុន្មានទៅមីង?

ខះមិនដឹងដែរហាមិនដឹងទុកបានអញ្ចឹងផង មិនដឹងអី។

កះចា៎!!អ្នកមីងអនុស្សាវរីយ៍អ្នកមីងចាំជាមួយម្ដាយអីគេវិញទៅហាឪពុក??ដែលស្រលាញ់គាត់ជាងគេហា៎??

ខះស្រលាញ់គាត់ជាងគេស្រលាញ់គាត់ត្រង់គាត់ស្លូត គាត់អញ្ចឹងទៅណាស់ គាត់អត់ចេះកាចនឹងកូនអត់ចេះនិយាយអីទេ!!និយាយតែមួយម៉ាត់ៗ!!

កះចា៎!!ដូចអ្នកមីង!!

ខះថែរក្សាកូន កូន១០គត់ ចិញ្ចឹមបានហើយអោយកូនមានគ្រួសារ ចែកទ្រព្យរបស់អីអោយសព្វគ្រប់ទាំងអស់អីចឹង !!

កះចា៎!!អីចឹងល្អណាស់អ្នកមីង!!

ខះចា៎!!

កះចុះសំរាប់ម្ដាយវិញឥឡូវគាត់នៅមានជីវិត?

ខះអត់មាននៅទេ!!ស្លាប់អស់ហើយ ស្លាប់អស់។

កះស្លាប់ពេលជំនាន់ណាដែរម្ដាយ?

ខះម្ដាយស្លាប់ពេល៨៣(១៩៨៣)៨៩(១៩៨៩)ហ្នឹងអូន ស្លាប់ពេលបែកអាពតហើយហ្នឹង។

កះចា៎!!គាត់ចាស់ដែរមែនឬក៏ម៉េច?

ខះចាស់ដែរអូន ចាស់ ម៉ាក់ញ៉ុមចាស់ដែរហ្នឹង។

កះហ្អ៎!ហើយពេលគាត់ស្លាប់ហ្នឹងអាយុប៉ុន្មានមីងចាំទេ?

ខះ៨៣។

កះ៨៣ឆ្នាំ??

ខះចា៎!!

កះតែប្អូនប៉ាទេអ្នកមីងណោះគាត់?

ខះហ៊ីប្អូនប៉ាញ៉ុមច្រើនណាស់!!

កះច្រើនដែរ ។

ខះប៉ាញ៉ុមចាស់បានការជាមួយគាត់ហ្នឹង ឃើញរូបថតបានដឹង។

កះហើយចុះអ្នកមីងស្រុកកំនើតរបស់អ្នកមីងដូចជាស្រុកកំណើតរបស់ពុកម្តាយគាត់នៅឯណាដែរអ្នកមីង?

ខះនៅហ្នឹងម៉ងអូន។

កះនៅស្វាយជ្រំហ្នឹងដែរ?

ខះនៅភូមិឃុំជាមួយគ្នាម៉ងអូន!!

កះហ៊ីៗ!!

ខះប៉ុន្តែប៉ាញ៉ុមឃុំចំបក់ គ្រាន់តែស្រុកជាមួយគ្នាណាស់ ឃុំខុសគ្នា។

កះចា៎!!

ខះភូមិក៏ខុសគ្នាដែរ។

កះតែសុទ្ធតែអ្នកនៅស្វាយរៀងជាមួយគ្នា?

ខៈហ្នឹងហើយនៅស្វាយរៀងជាមួយគ្នា។

កៈចា៎!!អ៊ីចឹងអ្នកមីងសំរាប់អើរតើមីងចងចាំអីគេខ្លាំងជាងគេជាមួយម្ដាយហា៎អ្នកមីង?

ខៈម្ដាយស្រលាញ់ត្រង់ម្ដាយស្លូតមិនចេះជេរ មិនចេះវ៉ៃកូន ប៉ុណ្ណឹងមានអីអោយហូបប៉ុណ្ណឹង។កៈចា៎!!

ខៈទោះបីពិបាកយ៉ាងណាក៏ទៅដែរ!!

កៈចា៎!!

ខៈស្លូតណាស់ម៉ាក់ញ៉ុម។

កៈហើយអ្នកមីងមានចាំទេថាម្ដាយអ្នកមីងគាត់ស្រលាញ់អ្នកណាជាងគេដែរម៉ាបងប្អូន??

ខៈញ៉ុមចាំថាគាត់ស្រលាញ់កូនទាំងអស់គ្នា
កូនទោះបីយ៉ាងណាក៏គាត់ស្រលាញ់ទាំងអស់គ្នាដែរ!!

កៈចា៎!!

ខៈទោះបីថាកូនច្រើនមែនតែថាកាន់ជើងកូនណាជាងកូនណាទេ!!

កៈអ៊ីចឹងស្រលាញ់គ្នាដូចគ្នាស្មើទាំងអស់?

ខៈចា៎!!!

កៈអ៊ីចឹងអ្នកមីងសំរាប់ចូលដល់យាយតាវិញម្ដងចាំទេថាយាយតាខាងឪពុកគាត់ឈ្មោះអីគេវិញមីង?

ខៈញ៉ុមអត់កើតទាន់ទេមីអូនអើយ!!

កៈអើយឪពុកម្ដាយមានដែលប្រាប់អីអត់?

ខៈប្រាប់ដែរប៉ុន្តែវាភ្លេច យូរហើយ។ខ្ញុំកើតអត់ទាន់តាយាយខ្ញុំផង។

កៈខាងឪពុកហ្នឹង?

ខ៖ខាងឪពុកអត់ដឹងទេ ខាងយាយខាងម្តាយបានដឹង។

ក៖បានដឹងហ៎?

ខ៖ចាំ!!

ក៖អ៊ីចឹតងខាងម្តាយគាត់ឈ្មោះតាអីយាយអីដែរអ្នកមីង?

ខ៖ឈ្មោះតាពេច យាយស៊ុម។

ក៖ចាំ!!ហើយគាត់សុទ្ធតែអ្នកស្រុកស្វាយរៀងដែរ?

ខ៖ចាំ!!នៅជាមួយគ្នាហ្នឹង។

ក៖ហើយអ្នកមីងមានអនុស្សាវរីយ៍អីគេខ្លះចាំជាមួយនឹងតាយាយ?

ខ៖តាយាយគ្មានតែម្តងយាយតាកាចៗណាស់ ធ្វើបាបម៉ាក់ញ៉ុមណាស់។

ក៖ម៉េចខ្លះទៅអ្នកមីងអាចនិយាយប្រាប់បន្តិចមើល??

ខ៖កូន ព្រោះគាត់មានប្រពន្ធពីរហាំ!!ម្តាយខ្ញុំហ្នឹងគាត់កូនមុនបានគាត់មានប្រពន្ធក្រោយទៀត គ្រាន់តែបាយមិនចង់អោយហូបផង ម៉ាក់ញ៉ុមឮម្តាយញ៉ុមគាត់ថាអញ្ចឹង!!ក៖ចាំ!!!ខ៖ពិបាក ប៉ុន្តែម្តាយញ៉ុមស្លូតមានបងប្អូន៤នាក់ម្តាយញ៉ុម។

ក៖ចាំ!!

ខ៖តែស្លាប់អស់ហើយគ្មាននៅផង។

ក៖ដោយសារការចាស់ជរាហ្នឹងមីងណោះ?

ខ៖ចាំ!!!ចាស់ហ្នឹងអត់មានរោគអីទេ!!

ក៖អ៊ីចឹងអ្នកមីងសំរាប់ចូលដល់ការរៀបអាពាហ៍ពិពាហ៍របស់អ្នកមីង អ្នកមីងរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីគាត់ឈ្មោះអីគេដែរ?

ខ៖ស្វាមីខ្ញុំឈ្មោះហ៊ែម សំអន។

ក៖ចាំ!!ហែម អីគេមីង?

ខ៖ហែម សំអិន។

ក៖ហែម សំអន?

ខ៖ហែម សំអិន។

ក៖សំអិន!!ឥឡូវគាត់នៅជាមួយអ្នកមីងសព្វថ្ងៃតើមីងហី?

ខ៖អត់ទេ បែកគ្នាយូរហើយអូន។

ក៖ហ៊ី!!ហើយហេតុអីបានបែកគ្នាមីងគាត់ស្លាប់ឬក៏អីអ្នកមីង?

ខ៖មានស្លាប់ទេបែកគ្នាតែម្ដង។

ក៖គាត់មានប្រពន្ធមួយទៀត?អីចឹងអ្នកមីងមូលហេតុបានបែកគ្នាជាមួយស្វាមីដែរ?

ខ៖គេមានស្រីមីអូន គេមានស្រីមានកូន២នាក់ គេមានស្រីបែកតាំងពីយើងជំនាន់បោះឆ្នោតយើងអ៊ុនតាក់ហ្នុំ!!

ក៖យូរណាស់ហើយ?

ខ៖យូរហើយ បែកតាំងពេលកូនញ៉ុមមីពៅនៅទូចហ្នឹង!!!!នៅទូចដែរហ្នឹងបែក។

ក៖ចាំ!!!

ខ៖គេទៅគេទៅធ្វើការរឿងគណបក្សគណអីឃោសនាណាស់!!

ក៖ចាំ!!

ខ៖ដល់ពេលទៅទៅបាត់អីចឹងទៅ!!

ក៖ហើយអត់ត្រលប់មកវិញទេចុះ?

ខ៖អត់ទេ!!ត្រលប់មកវិញក៏ខ្ញុំអោយបែកគ្នាម៉ងទៅ
ឥលូវនៅឈឺដេកដួលនៅជាមួយកូនហ្នុំ!!នៅជាមួយកូនរាល់ថ្ងៃហ្នឹងអីចឹង។

កៈជាមួយកូនអ្នកមីងជាមួយអ្នកមីងហ្នឹង?

ខៈហ្នឹងហើយ កូននៅផ្ទះហ្នឹង កូនប្រុសនៅផ្ទះហ្នឹងមាននប្រពន្ធហើយកូនញ៉ុមប៉ុន្តែនៅជាមួយហ្នឹងរាល់ថ្ងៃហ្នឹង
ប៉ុន្មានឆ្នាំហើយញ៉ុមមិនដែលទៅវីវរល់មិនដែលទៅជិតមិនដែលទៅសួរមិនដែលទៅរក។

កៈហើយអ្នកមីងបែកដាច់ស្រេចពីគាត់ម៉ង?

ខៈដាច់ស្រេច ដឹងមានអីចឹងជិត២០ឆ្នាំហ្ហ៎!!

កៈចំ!!

ខៈព្រោះអីកូនញ៉ុមតាំងពីមីទូច
ទូចដែរហើយយូរហើយតាំងពីអ៊ុនតាក់ចូលណោះ!!!ឃោសនាហ្នឹង!!

កៈចា៎!!

ខៈហ៎េមែនបោះឆ្នោតអ៊ុនតាក់ទេមីអូន!!មើលមួយអាណត្តិក្រោយទៀតហា៎!!

កៈហ្ហ៎!!៩៧ ១៩៩៧។

ខៈហ្នឹងហើយ។

កៈ១៩៩៧ បោះឆ្នោតម្តងទៀត។

ខៈម្តងទៀតព្រោះអី២ដង បោះមុនអ៊ុន តាក់ចូល មកក្រោយទៀតមកក្រោយទៀត!!

កៈចា៎!!

ខៈហ្នឹង!!

កៈហើយចុះមីងពេលគាត់បែកទៅប៉ុន្មានឆ្នាំបែកដំណឹងឆឹងម៉ងមីងហ៎េ??

ខៈបែកអត់បាត់ទេអូនញ៉ុមដឹងតែគ្រាន់តែឈប់ទាក់ទងគ្នាញ៉ុមឈប់អីទៅ
ចេះតែរកស៊ីចិញ្ចឹមកូនទូចៗទៅ។

កះហើយកូនសរុបទាំងអស់ប៉ុន្មាននាក់អ៊ីចឹង?

ខះកូនញ៉ុម៥នាក់តើអូន!!

កះនិយាយទៅការជាមួយគាត់តាំងពីឆ្នាំប៉ុន្មានអ្នកមីង??

ខះហ៊ឺតាំងពីបែកអាពតមកអូន ញ៉ុមការតាំងពីអាយុ១៧ ១៨ហ្នំ!!

កះហើយចេះតែដាច់ចិត្តទៅចោលកូន៥នាក់។

ខះកូនកាលហ្នឹងកូនវេទនាចង់ងាប់កូនញ៉ុមមីបងគេម៉ាក់មីមិញទៅនៅធ្វើការរោងចក្រទូច!!!! នៅជំទង់ប៉ុន្តែធ្វើការ ទៅធ្វើការទៅហើយខ្ញុំរកស៊ី ស៊ុយឈ្នួលស្ទូងស៊ីអីអ៊ីចឹងទៅណាស់អូនចិញ្ចឹមទំរាំបានធំៗ ដល់ពេលវាធំៗវាមករកស៊ីនៅភ្នំពេញហ្នឹងទៅបានមានគ្រួសារអស់ទៅបានធូរធារហ្នឹង។

កះចាំ!!!

ខះកាលមុនពីបាកណាស់អូនអើយ!!

កះពេលអ៊ីចឹងបានគាត់ត្រលប់មកវិញ?

ខះហ្នឹងហើយត្រលប់មកវិញក៏ខ្ញុំមិនអោយចូលផ្ទះដល់ពេលហើយឥឡូវឈឺដើរ ដេកដួល កូនៗផ្ញើរវេរលុយទៅអោយចាយទៅ!!

កះធ្វើម៉េចបើជាឪពុកទៅហើយមីងណោះ?

ខះចាំ!!ញ៉ុមថាអើរវាមិនដឹងថាវាកម្មពៀរស្អីទេ វានិយាយតាមធម៌ព្រះទៅណាស់!! អានេះវាអ៊ីចឹងទៅណាស់!!វាត្រូវអ៊ីចឹតងអោយវា ប៉ុន្តែញ៉ុមញ៉ុមគ្មានទាក់ទងអីទេកូនណាគេរាប់រាប់ទៅកូនណាគេមើលមើលទៅញ៉ុមអត់ដឹងទេ!!

កះចាំ!!ដាច់ដឹងហើយមីងហេ??ខះចាំ!!កះចុះអ្នកមីងពេលដំបូងពេលគាត់អត់ទាន់មានប្រពន្ធចុងអីវ៉ាន់គាត់ផ្តល់ក្តីស្រលាញ់អោយមីងច្រើនអត់?

ខះហ៊ីមីអូនហើយនិយាយអីចឹងដូចថាគ្មានទេអូននិយាយអីចឹងម៉ងទៅ!! គាត់ដើរតែផឹកដើរតែលេងអីចឹងទៅ បានតែគ្រួសារហ្នឹងពិបាក ដល់កូនធំៗទៅញ៉ុមចេះរកស៊ីក៏លែងពិបាកធូរធារទៅ កាលពីមុនគាត់អីចឹងគាត់ដើរផឹកមានពួកមានម៉ាក់អិចឹងមានស្រីញីអីចឹងរត់ឃាត់មិនបានទេ!! កះហ៊ីៗ!!ខះប៉ុន្តែយើងថាអញ្ចឹងនៅ ប៉ុន្តែមីនៅស្វាយរៀងនៅមានកូន២ធំៗហើយមីអូនណាស់សុខចិត្តចោលគេណាស់!!

កះហ៊ីៗ!!

ខះទៅណោះទៅណោះឡែរឡោរៗ!!

កះដូចអត់មានទិសដៅជីវិតមីងណោះ??

ខះហ្នឹងហើយ មិនដូចថាមិនមានអាណាគាត់មានទិសដៅជីវិតនៅជាមួយអ្នកណាមួយពិតប្រាកដហាំ!!

កះចាំ!!

ខះដល់ពេលអីចឹងទៅគេនៅជាមួយប្ដីគេទៅ!!កះហ៊ីៗ!!ខះអីចឹងហាំ!!

កះពិបាកដែរហ្នឹងដល់ពេលគាត់អត់មាននឹងផឹងហ្នឹង។

ខះមានហ្នឹងហើយ!!

កះអត់មានអាណាអោយប្រាកដហាំ!!

ខះហ្នឹងហើយ។

កះអីចឹងមីងដល់ពេលការជាមួយគាត់ហ្នឹង គេមានថ្លៃជំនូនអោយថ្លៃអីអត់អ្នកមីងដំបូង?

ខះហោជំនូនកាលហ្នឹងថោកទេ គេអោយតែមួយជីហ្នឹង មួយជីមាសហ្នឹងទេអូន។

កះចាំ!!

ខះជំនូនកាលហ្នឹងហាំ!!

កៈចាំ!!ហើយស្រលាញ់គ្នាដោយចិត្តឯងឬក៏មានម៉ែឪចូលស្តីដណ្តឹង?

ខៈមិនដែលដឹងចិត្តឯងផងហ្នឹង ម៉ែឪ ម៉ែឪចាស់ៗរៀបចំអោយរៀបចំហ្នឹង!!

កៈហ៊ីៗ!!

ខៈកាលហ្នឹងកូនបងប្អូនហ្នឹងអ៊ីចឹង ស្រុកនៅហ្នឹងគេអត់មានថាដើរហើអញ្ចេះអញ្ចុះ វហៃររហូតអីទេ ស្រេចតែម៉ែឪរៀបចំអោយស្រេចលើគាត់ហ្នឹងហាំ!!

កៈចាំ!!

ខៈបងប្អូនញ៉ុមអ៊ីចឹង។

កៈហ៊ីៗ!!ស្រេចលើម៉ែឪអ៊ីចឹងទៅ!!

ខៈកូនញ៉ុមមីបងគេ!!

កៈអ្នកមីងបានកូនថៅសុទ្ធតែស្អាតៗអ្នកមីង!!ភ្នែកអ្នកមីងដូចនេះដូចមិនមែនជនជាតិខ្មែរដូចកាត់
ដោយសារភ្នែកពណ៌ស្អាត!!អ៊ីចឹងអ្នកមីងបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីមានកូន៥នាក់អ្នកមីងណោះ?

ខៈចាំ!!

កៈមីងអាចរៀបរាប់ឈ្មោះកូនតាំងពីពៅរហូតដល់បងគេអ៊ីចឹងហាំ??

ខៈមីបងឈ្មោះថារ៉ា!!

កៈចាំ!!

ខៈអាប្រុសមួយទៀតរដ្ឋា ហើយអាទី៣អារក្សា នៅផ្ទះអាបញ្ញាហើយមីនេះមីរចនា។

កៈចាំ!!ត្រកូលអីវិញដែរអ្នកមីងពួកគាត់?

ខៈត្រកូលហៃមទាំងអស់អូន កាន់ត្រកូលខាងពុក។

កះចាំ!!អ៊ីចឹងអ្នកមីងសំរាប់កូនចៅរបស់អ្នកមីងហាំ!!អ្នកមីងមានបានអោយគាត់ទៅសិក្សាទាំងអស់គ្នាអត់?

ខះបានតិចៗណាស់អូនអើយ!!គ្មានបានរៀនអីទេអូន បានរៀនត្រឹមថ្នាក់ទី៥ទី៦ហ្នឹង បើមីបងគេគ្មានបានរៀនផងហ្នឹង !!អត់បានរៀនផង !!

កះចាំ!!

ខះមីនេះរៀនបានត្រឹមថ្នាក់ទី១ទី២អត់មានចេះផងហ្នឹង មានអាណាចេះ ចេះតែអាប្រុស អាប្រុសគ្រាន់បានមើលបានហ្នឹង!!យើងកាលណោះពិបាកចង់ងាប់ហ្នឹងគ្មានរកអីអូន។

កះចាំ!!

ខះកូននៅទូចៗម្នាក់ឯងហ្នឹង
មានអ្នកណានៅដើរលិចដើរកើតវាគ្មានអាណាអោយកូនបានរៀនច្រើនអីជ្រៅជ្រះទេ!!

កះចាំ!!ហើយអ្នកមីងបើសិនជាពុក ដូចជាប្តីអ្នកមីងនៅជុំគ្នាមីងក៏មិនពិបាកដែរមីងណោះ?

ខះអត់ពិបាកអត់អី!!យើងមិនដឹងដែរយើងមើលមិនឃើញមិនដឹងដែរ។

កះអ៊ីចឹងអ្នកមីងពេលនៅក្នុងជីវិតអ្នកមីងតើមីងធ្លាប់រកស៊ីអីគេខ្លះដែរ?

ខះញ៉ុមមុនដំបូងរកស៊ីមានអី លក់លៀសលក់អីហ្នឹងអូន ប៉ុនរក!!

កះអ្នកមីងសព្វថ្ងៃលក់លៀសដែរហេ?

ខះចាំលក់លៀសលក់នំប៉ុណ្ណឹង!!

កះហ្ហ៎!!អើរថ្ងៃហ្នឹងអត់បានទៅលក់លៀសទេអ្នកមីងហោ៎??

ខះគ្មានបានលក់ឯណាអូន។

កះមេឃភ្លៀងអ៊ិចឹងទៅ?

ខះមេឃភ្លៀងតាំងពីព្រឹក។

ក៖អ៊ីចឹងមានបានទទួលលៀសពីគេតាំងពីព្រឹកអីអត់?

ខ៖បានតាំងពីយប់តើអូន!!

ក៖ហ្ហ៎!!

ខ៖គេដាក់អោយតាំងពីយប់ហ្ហ៎!!ប៉ុន្តែអត់បានទៅលក់ទេ!!

ក៖ហើយដល់ពេលអត់បានទៅលក់ដល់ពេលមានមេឃភ្លៀងអ៊ីចឹងទៅមីងធ្វើម៉េចទៅអ៊ីចឹង?

ខ៖ប្រស់ទុកទៅ!!

ក៖ប្រស់អីវ៉ាន់ទុកដែរមីងហេ៎??

ខ៖រស់តើអូនមានអី!!ក្លាសេទុក
នៅពេញពេញទុកហ្ហ៎ដាក់ទឹកកកទៅអោយវាត្រជាក់ទៅវាមានងាប់អី!!

ក៖ចា៎!!អូយអ៊ីចឹងល្អណាស់អ៊ីចឹង
!!ញ៉ុមស្មានតែមកបើសិនជាអត់មានបើកថ្ងៃមកវាងាប់អស់រលីង!!

ខ៖អត់ទេអត់ងាប់ទេ!!

ក៖ចា៎!!ចុះអ្នកមីងសំរាប់ជីវិតរបស់អ្នកមីង
ឥឡូវនិយាយពីសង្គ្រាមដោយសារអ្នកមីងដឹងតែកើតជំនាន់សង្គ្រាមទាន់ហើយអ្នកមីងណោះ??

ខ៖ចា៎!!

ក៖អ្នកមីងកើតជំនាន់លន់ នល់ទាន់ទេ?ចាំពីរបបហ្នឹង??

ខ៖អត់ទាន់ទេអូន អត់ទាន់ទេ វាស្រពិចស្រពិលញ៉ុមអត់ដឹងដែរហ្នឹង។

ក៖ចា៎!!ហើយឥឡូវដល់ជំនាន់ប៉ុល ពតវិញម្តង មីងចាំអីគេខ្លះពីជំនាន់ប៉ុលពតអាចរៀបរាប់អោយបានក្បោះក្បាយទុកអោយកូនអ្នកមីងស្តាប់ថាអ្នកមីងឆ្លងកាត់រឿងអីគេខ្លះអ៊ីចឹងហា៎??

ខះជំនាន់ប៉ុល ពតហេ៎??

កះចា៎!!

ខះអើយពុកញ៉ុមហើយម្តាយញ៉ុម គេដេញអោយទៅនៅឯវាល ទៅនៅក្នុងសាលាណោះ!!

កះចា៎!!

ខះគេមិនអោយនៅភូមិណា ផ្ទះគេរើរអស់!! គេយកទៅហា៎!!ក៏រើរអស់មកវិញដឹកគេដឹកស្រូវដឹកគេបន្ទាប់មកមិនបែក!

កះហ៊ឺៗ!!

ខះបែកមកបានដឹកអីវ៉ាន់មកវិញហ្នឹង ដឹកមកគ្មានអីទេបងប្អូនច្រើនផងប៉ាញ៉ុមទៅរកពោត រកជំឡូងមកបបរ បងប្អូនច្រើនណាស់កាលហ្នឹង ទំរាំតែនឹងបានមកសព្វថ្ងៃ ហ្នឹងពិបាកណាស់អូនអើយ!!

កះចា៎!!ហើយអ្នកមីងមានដែលឃើញពួកប៉ុល ពតយកមនុស្សទៅសម្លាប់ចោលអីអត់??

ខះអត់ដែលឃើញអត់អូន អត់ដែលឃើញ។

កះចា៎!!

ខះឮតែគេថា បើថាឃើញផ្ទាល់នឹងភ្នែកអត់ដែលនៅទូចៗទេ អត់ដែល។

កះចុះអ្នកមីងការហូបចុក តើអ្នកមីងអាចនិយាយពីការហូបចុកអ្នកមីងទទួលបានម៉េចដែរការហូបចុកហា៎??

ខះការហូបចុកជំនាន់អាពតអូន?

កះចា៎!!

ខះមានអីទេ ព្រោះអីញ៉ុមបានបងប្អូនខាងបងថ្លៃញ៉ុមធ្វើការខាងហ្នឹងខាងសន្តិសុខខាងពួកផ្គត់ផ្គង់ខាងបាយទៅណាស់!!

ក៖ហ៊ឺៗ!!

ខ៖អត់អីទេ។

ក៖អីចឹងគេអោយហូបស្រួលប្រួលធម្មតាអីចឹងទៅ?

ខ៖ហូបស្រួលប្រួលធម្មតាទេ!!

ក៖ចាំ!!!

ខ៖អើរគ្រាន់ថាវាមិនពេញលេញល្អហាំគ្រាន់ថាវាបានជាងគេវាមិនសូវថាគេចែកមួយវែកមួយអីគ្មានទេ!!គ្រាន់តែបានមួយឆ្អែតមួយឆ្អែតហ្នឹង ប៉ុណ្ណឹង!

ក៖ហ៊ឺៗ!!អ្នកមីងពេលហ្នឹងអ្នកមីងធ្វើការអីគេដែរ?

ខ៖មានធ្វើការអីទេអូននៅទូចៗហ្នឹង មើលក្មួយ ក្មួយទូចប៉ុណ្ណឹងដែរ!!មើលកូនបងញ៉ុម។

ក៖ហើយមានដែលគេធ្វើទារុណកម្មអីឬក៏អីអត់មីង?

ខ៖អត់ដែលអូន អត់ដែលផង អត់ដែលជួបទេ!!

ក៖ចាំ!!ពេលអ្នកមីងនៅក្នុងជំនាន់ប៉ុល ពតនៅខេត្តណាវិញ?

ខ៖នៅខេត្តស្វាយរៀងដដែលហ្នឹងអូន!!

ក៖គេអត់មានជំលៀសចេញទៅឆ្ងាយ?

ខ៖អត់មានជំលៀសចេញទៅណាទេ!!

ក៖ចុះឪពុកម្តាយរបស់អ្នកមីងមានគេយកទៅធ្វើបាបធ្វើអីអត់មីង?

ខ៖ម្តាយញ៉ុមគេធ្វើបាបអូន។

ក៖ម៉េចខ្លះទៅអ្នកមីង?

ខ៖គេអោយគាត់ទៅច្រូតដល់ម៉ោង២ម៉ោង១អោយទៅច្រូតនៅមាត់ព្រៃកហ្នំ!!មាត់ព្រៃកកាលហ្នឹងម្តាយញ៉ុមចាស់ហើយហ្នឹង។

ក៖ហ៊ឺៗ!!

ខ៖ពិបាកណាស់ម្ដាយញ៉ុមនោះ ពុកញ៉ុមមិនសូវពិបាកទេ!! គាត់មិនសូវខ្លាចគាត់មិនសូវពីបាកទេ!!ម្ដាយញ៉ុមខ្លាចគេណាស់!!

ក៖ហ៊ឺៗ!!

ខ៖ខ្លាចគេយកទៅវ៉ៃចោលវ៉ៃអី ចេះថាគេយកទៅអញ្ចេះអញ្ចុះគាត់ខ្លាចហាំ!!

ក៖ចាំ!!

ខ៖ដល់ពេលឪពុកញ៉ុមអត់ទេ!! អត់សូវពិបាកទេ!!គាត់នៅផ្ទះនៅអីវិញខ្សែវិញអី បើថាម្ដាយញ៉ុមដើរសព្វគ្រប់ហ្នំ!!

ក៖ចាំ!!

ខ៖ដើរទាំងយប់ទាំងយប់ ទាល់តែម៉ោង១ម៉ោងអីឡើងទៅហើយម៉ោង៧ ៨ ម៉ោង១០អីបានមកផ្ទះ មិនដឹងបាយទឹកអីណាទេ ខ្ញុំនៅទូចដែរធ្មើរហ្នឹងដេកលក់ហើយអូនអើយ!!

ក៖ហើយមីងមានអ្នកណាមើលអីទេ??

ខ៖ខ្ញុំអី?

ក៖ហ៊ឺៗ!!

ខ៖ខ្ញុំធំហើយដែរអូន មិននៅនេះទេ ញ៉ុមបានមើលក្មួយប៉ុននេះហើយហ្នឹង ព្រោះថាញ៉ុមនៅចាំខ្លះប៉ុណ្ណឹង។

ក៖ចាំ!!ហើយមីងមិនដែលឃើញអ្នកណាគេយកមនុស្សចងទាំងខ្សែទាំងខ្សែដើរអីអត់?

ខ៖អត់ទេ អត់ដែលទេ អត់ដែលឃើញទេ អត់ដែលទេ។

ក៖អ៊ីចឹងរស់នៅដូចជាអត់សូវអ្នកមីងអត់សូវភិតភ័យដែរហេំ??

ខះញ៉ុមអត់សូវភិតភ័យទេអូនធម្មតា គ្រាន់តែទៅក្មួយព្រលឹមឡើងអ៊ីចឹងម៉ោង៨ ៩ ១០ហ្នឹងយកទៅហូបបាយទៅ យកទៅពរក្មួយទៅហូបបាយទៅក្មួយញ៉ុមប៉ុនៗនេះមានទូចមានធំ២នាក់ហ្នំកូនបងញ៉ុមហ្នំ!!

កះហ៊ឺៗ!!

ខះញ៉ុមនៅមើលនៅជាមួយហាំ!!

កះចាំ!!

ខះញ៉ុមនៅមើល។

កះអ៊ិចឹងជីវិតអ្នកមីងហោងខ្លាំងមែនទែនហាំ!!

ខះហ្នឹងហើយ
ចាំអត់ដែលមានធ្វើអីទេដូចថាយើងអានេះវាតាមព្រេងសំណាងយើងដែរណាស់!!

កះចាំ!!

ខះយើងធ្វើល្អបានល្អគេអត់សូវដែលធ្វើបាបធ្វើទោសអីយើងទេ!!

កះមីងដូចពួកប៉ុល ពតហ្នឹងល្បាតពេញភូមិម៉ងឬក៏ម៉េច?

ខះអត់ទេអត់ដែលឃើញផងអូន។

កះមិនសូវដែលឃើញណាប៉ុន្មានដែរហោ?

ខះអត់សូវដែលឃើញទេ ប៉ុន្តែនេះវាខុសភូមិខុសឃុំអីអ៊ីចឹងហាំ!!អ៊ីអត់ដឹងដែរអូនណាស់!!

កះចាំ!!

ខះប៉ុន្តែភូមិហ្នឹងអត់សូវអីដែលហ្នឹង ភូមិបឹងស្លាហ្នឹងហ្នំ!!

កះហ៊ឺៗ!!

ខះរវល់តែគេយកបងៗញុំមគេយកទៅកងចល័ត
កាលហ្នឹងលើកដីលើកអីបងៗញុំមហ្នឹងហាំ!!កះចាំ!!

ខះហើយម៉ាក់ប៉ាពុកខ្ញុំក៏នៅផ្ទះដែរ។

កះចាំ!!ចុះអ្នកមីងមានបងប្អូនអ្នកមីងមានអ្នកណាគេស្លាប់នៅ!!អត់មានស្លាប់នៅជំនាន់ប៉ុល ពត?

ខះអត់!!ជំនាន់ប៉ុល ពតអត់មានអ្នកណាគេស្លាប់ទេមីអូន។

កះហើយមានដែលអ្នកណាគេប្រាប់ថាធ្វើបាបអីអត់?

ខះអត់ទេ។

កះអ៊ិចឹងសុទ្ធតែស្រួលទាំងអស់?

ខះសុទ្ធតែស្រួលទាំងអស់ !!

កះអូយសំណាងម្ល៉េះ!!

ខះបានគុណទេវតាជួយហើយ អត់សូវធ្វើបាបក្នុងជំនាន់អាពតទេ បងប្អូនញុំមច្រើនមែនតែអត់ដែលអាណាធ្វើបាបទេ!!

កះហ៊ឺ!!ហេងហើយ !!មីងភូមិហ្នឹងនៅជិតព្រំប្រទល់វៀតណាមអត់?

ខះអត់ទេនៅឆ្ងាយដែរតើអូន!!

កះហ្ហ៎!!

ខះឆ្ងាយពីវៀតណាមដែរ។

កះចាំ!!

ខះមិនមែននៅទល់ដែនទេ!!

ក៖ចាំ!!អឺចឹងអ្នកមីងសំរាប់ក្រុមគ្រួសារទាំងមូលអឺចឹងពេលបែកជំនាន់ប៉ុល ពតមកមានអារម្មណ៍ម៉េចដែរ??

ខ៖មានអីសប្បាយចិត្ត បងៗញ៉ុមកាលគេរត់បែកគ្នាដែរហ្នឹងពីរបីថ្ងៃបានរកគ្នាឃើញដែរ គ្នាច្រើនណាស់!!

ក៖ចាំ!!មីងចាំពេលទិដ្ឋភាពពេលវៀតណាមចូលមកស្រុកខ្មែរទេ?

ខ៖ចាំតើអូន។

ក៖ម៉េចដែរអ្នកមីងអាចរៀបរាប់ប្រាប់!!

ខ៖ដល់ពេលញ៉ុមទៅពួនកន្លែងឃុំគេនោះទៅពួនម៉ែញ៉ុមឪញ៉ុមពុកញ៉ុមម្ដាយញ៉ុមទៅនិយាយ ពីលឺសូរគ្រាប់កាំភ្លើងភ័យចង់ដាច់ខ្យល់ថាហ្អ៎ថយទៅកើតវិញថយទៅកើតវិញ បានរត់មកវិញតើ!!

ក៖ហ៊ឺ!!

ខ៖ញ៉ុមនៅទូចៗដែរហ្នឹង។

ក៖ចាំ!!

ខ៖ហើយគោ កាលហ្នឹងគោទាំងរ៉ូងបាត់អស់រលីង។

ក៖វាផ្អើលទៅណាទៅមីង?

ខ៖ចុះដឹងអីយើងប្រលែងយើងលែងគិតលែងគូរអីហើយហើយអាខ្លះគេចាប់ធ្វើស៊ីធ្វើអីអឺចឹង ទៅណាស់។

ក៖ហ៊ឺ!!

ខ៖វាព្រៃវាប្រលែងពេញទេសពេញស្រុកគ្មានអាណាទៅគិតគូររឿងគោក្របីអី។

ក៖អូយទិដ្ឋភាពពេលហ្នឹងមិនដឹងវេទនាប៉ុណ្ណាទេមីង?

ខ៖ហ្នឹងហើយ។

ក៖អនោចអធម្មស្រុកខ្មែរ។

ខ៖ទំរាំបានប៉ុន្មានមករកគោរកអីបានចិញ្ចឹមវិញហ្នឹងពិបាកដែរហ្នឹងហាំ!!

ក៖មីងដូចបែកប៉ុលពតមកដូចចិញ្ចឹម ធ្វើស្រែដដែលហេ?

ខ៖ធ្វើស្រែដដែលហ្នឹងអូន មិនដែលរកអីទេ ពុកម៉ែញ៉ុមមិនដែលរកអីផងហ្នឹង ធ្វើតែស្រែធ្វើតែចំការហ្នឹង!!

ក៖ចាំ!!

ខ៖ប៉ុន្តែគ្រាន់តែដីគាត់ច្រើន ប៉ុន្តែដល់បែកអាពតមក ចាប់បានដីច្រើនដែរដល់ហើយគេចែកទៅបានតិចទៅ ឥឡូវបើចែកកូនគ្រប់គ្នាក៏អស់ទៅ។

ក៖ចាំ!!អ៊ីចឹងបងប្អូនទាំងអស់សុទ្ធតែនៅក្នុងស្រុកហ្នឹងទាំងអស់?

ខ៖នៅស្រុកទាំងអស់អត់មានបែកគ្នាទៅណា!!

ក៖ចាំ!!អ៊ីចឹងតាំងពីកើតមកពួកគាត់អត់មានផ្លាស់ប្តូរទៅណាទេមីងហ្នំ!!

ខ៖ហ្នឹងហើយគ្មានផ្លាស់ប្តូរទេអូន។

ក៖ភាគច្រើនអ្នកស្រុកនោះគេរកស៊ីអីគេដែរមីង?

ខ៖មានរកអីទេមានតែធ្វើស្រែចំការហ្នឹងអូន គ្មានរកអីផង នៅតែរាល់ថ្ងៃអ៊ីចឹងដែរ។

ក៖ធ្វើតែស្រូវ។

ខ៖ចាំធ្វើតែស្រូវ។

ក៖អត់មានដាំអីទៀតណាមីង?

ខ៖តែគាត់ចិញ្ចឹមមាន់ ចិញ្ចឹមទា គោក្របីអីច្រើនៗទៅទុកដោះដូរអ៊ីចឹងទៅណាស់!!ក៖ហ្នំ!!ខ៖គាត់សុទ្ធតែធូរធារអត់មានបងប្អូនណាពិបាកទេ!!

ក៖ចាំ!!អ៊ីចឹងអ្នកមីងសំរាប់អ្នកមីងរើរមកនៅភ្នំពេញរយៈពេលអស់ប៉ុន្មានឆ្នាំហើយ?

ខ៖អើរយូរដែរហ្នឹងអូន
១០ឆ្នាំហើយនិយាយអញ្ចេះទៅ!!ក៖ចាំ!!ខ៖តាំងពីបងញ៉ុមនៅទូចហ្នំ!!មក
មកមើលកូនមើលចៅទៅមើល កូនញ៉ុមរកស៊ីអញ្ចឹងទៅ។

ក៖ចាំ!!អញ្ចឹងអ្នកមីងសំរាប់របរលក់លៀសមីងលក់អស់ប៉ុន្មានឆ្នាំហើយឥឡូវ?

ខ៖៤ ៥ ឆ្នាំដែរញ៉ុមមិនដឹង!!

ក៖ចាំ!!ហើយម៉េចដែរការចំនេញអីពីមួយហ្នឹងបានច្រើនគ្រាន់បើទេមីង?

ខ៖បានម៉ាចាយបានម៉ាគួរសមដែរតើអូន!!

ក៖ហ្នំ!!

ខ៖បានយើងដោះដូរបានហូបចុកអីបានសល់ខ្លះអ៊ីចឹងទៅអូន
អាចជីវភាពយើងបានធូរធារបានជាងមុន។

ក៖ចាំ!!អ៊ីចឹងអ្នកមីងបានជួយគ្រួសារមិនតិចដែរទេអ៊ីចឹង??

ខ៖ចាំ!!

ក៖អ៊ីចឹងអ្នកមីងសំរាប់ផ្ទះនៅនេះជួលគេឬក៏មីងទិញដាច់?

ខ៖ជួលតើអូន!!

ក៖មួយខែគេយកប៉ុន្មានដែរ?

ខ៖មួយខែផ្ទះហ្នឹងគេយក៣៥ផ្ទះហ្នឹង ផ្ទះខាងណោះ៤០អូន ២បន្ទប់នេះជាប់គ្នា។

ក៖ចាំ!!ហើយដីហ្នឹងជាដីរបស់រដ្ឋឬក៏ជាដីរបស់ឯកជនមីង?

ខ៖ដីម្ចាស់ផ្ទះគេ ដីឯកជនតើអូន។

កៈហ្ហ៎!!ហ្នឹងហើយ អ៊ីចឹងអ្នកមីងសំរាប់ដូចជាសំរាប់ការសិក្សារបស់មីងវិញម្ដងមីងរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខៈអត់បានរៀនផងមីអូន អ៊ីមានចេះអក្សរណា!!កៈហ្ហ៎!!ខៈអត់បានចេះអត់មានបានរៀនផង!!

កៈអ៊ីចឹងពីដើមមក!!

ខៈកើតមកចំប៉ុល ពតម៉ង ដល់ធំឡើង ចំជំនាន់ប៉ុល ពតម៉ងគ្មានដែលបានរៀនសូត្រអីទេ!!ទទេតែម្ដង!!

កៈហ៊ឺ!!

ខៈបែកមកធំដែរលែងទៅរៀនអ៊ីចឹងទៅ!!

កៈចា៎!!

ខៈបងប្អូនច្រើនម៉ែ ពុកម៉ែក៏ពិបាកក៏លែងទៅរៀន អ៊ីចឹងអ្នកមីងសំរាប់អ្នកមីងពេលនៅពីក្មេងហា៎!!ធម្មតាពេលជីវិតមនុស្សអត់ទាន់បានរៀនក៏ដោយ មានដែលស្រម៉ៃចង់ធ្វើពេលធំឡើងចង់ធ្វើអីគេអត់មីង?

ខៈចង់ធ្វើ ដូចអត់មានចង់ធ្វើអីគេទេ!! ចង់លក់ដូរអីធម្មតាអ៊ីចឹងអូន។

កៈរកស៊ីអីអ៊ីចឹងទៅ?

ខៈចា៎ហ្នឹងហើយ!!

កៈអត់ដែលគិតបំណងប្រាថ្នាធ្វើអីទេហេ៎?

ខៈអត់ដែលគិតធ្វើ បំណងប្រាថ្នាធ្វើមានធ្វើបានអីទេទៅណាទេ!!ព្រោះដឹងថាខ្លួនឯងធ្វើវាមិនបានអីអ៊ីចឹងហា៎!!

កៈតែអត់អី!!អ្នកមីងទោះតែនេះអ្នកមីងនៅតែសាច់ឈាមស្រស់ស្អាត ស្រស់ថ្លាអីអ៊ីចឹងហា៎!!ហ្នឹងហើយ អ៊ីចឹងអ្នកមីងសំរាប់ការលក់ហ្នឹងហា៎ អ្នកមីងលក់នៅពេញទីក្រុងភ្នំពេញម៉ងឬក៏ដើរទៅដល់ណាខ្លះមីង?

ខះហ៊ីដើរជិតៗហ្នឹងដែរហ្នឹងអូន!!ទូលទំពូង ត្រលប់មកនេះដើរជិតៗដែរហ្នឹង អីដើរតែមួយម៉ោងពីរម៉ោងដែរហ្នឹង ដើរមិនយូរដែរហ្នឹង។

កះហ្ហ៎!!អីចឹងដាច់ណាស់មីងណោះ??

ខះលក់តិចៗដែរហ្នឹងអូន។

កះមួយថ្ងៃអស់ប៉ុន្មានតៅដែរមីង?

ខះ១តៅហ្នឹងនៅរើសសំបកនៅរើសលៀសស្អុយនៅសល់លៀសតិចៗដែរហ្នឹង ចំនេញបានមួយថ្ងៃ២០០០០
៣០០០០អីហ្នឹង២០០០០ទាំងនំទាំងអីចំនេញបាន២០០០០ហ្នឹង។

កះលក់ទាំងនំផងលក់ទាំងលៀសហាលផង?

ខះចា៎!!

កះហ៊ីឆ្លាតណាស់មីង!!អីចឹងបានគ្រប់ ដូចជាលុយទាំងអស់ហ្នឹងផ្គត់ផ្គង់សំរាប់កូនដែលនៅលីវឬក៏ម៉េច?

ខះអត់ទេ
អត់!!ផ្គត់ផ្គង់ខ្លួនឯងអត់ដែលអោយកូនណាហើយក៏គ្មានដែលចាយវាយអីទៅណាដែរថ្លៃបាយម្ហូបអីលើកូន!!

កះហ្ហ៎!!

ខះកូនបងហ្នឹងទិញអោយញុំា។

កះអីយ៉ាស់មីងមានណាស់នេះ!!

ខះអត់ដែលយកទៅណាអីទេ លុយកាក់អី!!

កះគ្រាន់តែលុយបានមកសន្សំទុកអញ្ចឹងទៅមីងណោះ??

ខះចា៎!!សន្សំទុកតែខ្លួនឯងហ្នឹងមីអូន!!

កះហើយមានអោយចៅញុំាអី!!

ខះចៅមានអីចម្មតាអោយញុំា អោយអីអោយតែត្រូវការអីអោយដែរ។កះចា៎!!ខះប៉ុន្តែម៉ាក់ប៉ាវាលក់ដែរ មានតែគេអោយខ្ញុំ បើខ្ញុំអោយកូនមិនសូវទេ!!

កះចា៎!!ហើយអ្នកមីងមានផ្ទះអីនៅស្វាយរៀងអីនៅណោះអត់?

ខះមានតើអូន!!

កះផ្ទះណោះមានអ្នកណាគេអ្នកនៅវិញទៅ?

ខះបងញុំមនៅ២នាក់អូន។

កះតែជាទ្រព្យសម្បត្តិរបស់អ្នកមីងទេ?

ខះចា៎!!ប៉ុន្តែញុំមនៅជាមួយបងបងញុំមហា៎ បងនៅលីវ២នាក់ កូនគ្មានកូនគ្មានចៅអីទេនៅរាល់ថ្ងៃហ្នឹង!!!

កះនៅលីវ២នាក់?

ខះចា៎!!

កះអត់ព្រមយកប្តីសោះម៉ងហេ?

ខះអត់ទេ!!អាយុ៦០ ៦០ជាង៥០ជាង អីទៅហើយ!!កះហ្ហ៎!!!ខះចាស់ៗហើយ។

កះហើយម៉េចបានគាត់អត់គិតយកប្តីយកអីមីងណោះ??

ខះមិនដឹងទេអូនអើយដូចថាវាគ្មានទំនង គ្មានព្រេងអីអ៊ីចឹងដូចថាគេសួរគាត់ ជំនាន់អាពតគាត់មិនព្រមការ។

កះគេអត់យកទៅធ្វើអីដែរមីងហេ?

ខះគេអត់យកធ្វើអីទេ !!

ក៖អ្នកខ្លះ!!

ខ៖ដល់ពេលគាត់ប្រកែកអីចឹងក៏គេមិនហ៊ានបង្ខំគាត់ដែរហ្នឹង សំណាងដែរដូចទេវតាជួយយើងដែរ។

ក៖ហ៊ី៎!!អីចឹងអ្នកមីងសំរាប់ជីវិតអ្នកមីងហា៎!!អ្នកមីងគិតថាពេលវេលាវេទនាខ្លាំងបំផុតមីងគិតថាពេលណាដែរ?

ខ៖ពេលអើរប្តីទៅមានស្រីហ្នឹងវេទនាកូននៅទូចៗពិបាកណាស់ពិបាកមែនទែន ដើរ!!

ក៖អ្នកមីងធ្វើម៉េចដើម្បីឆ្លងកាត់ដែរ?

ខ៖ដើរស៊ីឈ្នួលស្ទូងគេអីចឹងបានអង្ករមកចិញ្ចឹមកូនៗទំរាំតែកូនៗធំៗទៅ
មីបងចេញមកពីធ្វើការរោងចក្រ
ទំរាំបានធំមកយូរទៅវាបានធ្វើការទាំងអស់គ្នាវាចេះមករៀនមករកស៊ីទៅបានធូរធារវិញអូន!!ពិបាកមែនទែនដែរហ្នឹង!!

ក៖ចា៎!

ខ៖កាលនៅកូនទូចៗ។

ក៖ហ៊ី៎!!ចុះសប្បាយមីងពេលវេលាដែលសប្បាយបំផុតហា៎??

ខ៖សប្បាយបំផុតមានតែពេលកូនធំៗហើយបានការកូនការអីមានសប្បាយចិត្ត
ទាល់តែឥឡូវហ្នឹងអត់មានពិបាកចិត្តអីទេ លែងពិបាកចិត្តអី។

ក៖ចា៎!!អីចឹងគ្រាន់តែដឹងតែរកស៊ីបានលុយមកចាយ។

ខ៖បានលុយមកទុកចាយតែខ្លួនឯងអីតែខ្លួនឯងហ្នឹង!!

ក៖ចា៎!!ហើយចៅឥលូវសរុបមកប៉ុន្មាននាក់ហើយមីង?

ខ៖៧ហើយ។

ក៖ផ្ទះកូនចៅមីងនៅម្តុំៗហ្នឹងទាំងអស់ឬក៏ម៉េចដែរ?

ខះអត់ទេនៅបន្ទាយដែក។

កះបន្ទាយដែកនៅណាវិញទៅមីង?

ខះបន្ទាយដែកនៅចំការហ្នំអូន កូន កូនស្រី២នាក់មានប្តីនៅចំការទាំងអស់ហ្នឹងមានអាប្រុសមួយក៏មានប្រពន្ធនៅហ្នឹងដែរ។

កះចាំ!!

ខះនៅស្វាយរៀងតែមួយទេ!!ហ៊ែម បញ្ញានៅស្វាយរៀងមានប្រពន្ធនៅហ្នឹង!!កូនពីរនាក់ពីរនាក់មួយពីរអស់ហើយហ្នឹង ចៅញ៉ុម ចាំ!!

កះចាំហ្នឹងហើយចុះអ្នកមីងចំណង់ចំណូលចិត្តអ្នកមីងចូលចិត្តពិសារម្ហូបអីគេដែរ?

ខះញ៉ុមអី??មានតែប្រហុកប្រអកអីស្រុកខ្មែរហ្នឹង ថាសម្លរនេះមិនដែរអី!!

កះគ្រឿងអីត្រលានៗអត់សូវចូលចិត្តទេមែនទេ?

ខះអត់ទេ អត់ចូលចិត្តទេ។

កះហើយអ្នកមីងចេះ!!ឥឡូវម្ហូបរើសតែមួយមីងពេញចិត្តជាងគេគឺអីគេ?ប្រហុកឬក៏អីគេ?

ខះសម្លរម្ជូរព្រលិតសម្លរអីហ្នឹង។

កះអ៊ិចឹងអ្នកមីងម្ហូបភាគច្រើនមីងចូលចិត្តមីងចេះធ្វើទាំងអស់អត់?

ខះធ្វើចេះ ប៉ុន្តែគ្រាន់តែធ្វើហូបក្នុងក្រុមគ្រួសារឯងអូនគ្រាន់តែមិនចេះធ្វើចុងភៅណាអត់ចេះទេចេះតែអាម្ហូបគ្រួសារឯងចេះតែប៉ុណ្ណឹង។

កះចាំ!!ហ្នឹងហើយ!!អ៊ីចឹងអ្នកមីងតាំងពីតូចរហូតដល់ធំមកជីវិតដែលអ្នកមីងលំបាកគឺពេលមីងមានប្តីហើយប្តីមានស្រី??

ខះចាំហ្នឹងហើយ!!ពិបាកតែប៉ុណ្ណឹងទេបើថាខ្ញុំពីទូចញ៉ុមអត់ដែលពិបាកទេ!!ពុកម៉ែញ៉ុមអត់ដែលអោយពិបាកទេ អត់ដែលអោយកូនដើរទៅណាទេ!!ពិបាក ពិបាកពេលហ្នឹងអូន។

កះចាំហ្នឹងហើយ។

ខ៖តែប៉ុណ្ណឹង!!ឥឡូវដល់ពេលមកកូនការហើយអស់សប្បាយចិត្តជាងគេរាល់ថ្ងៃហ្នឹងមានចៅមានអីហ្នឹង សប្បាយចិត្តមានលុយ!!

ក៖ចាំ!!

ខ៖មានលុយមានអីចាយហ្នឹងលែងកើតទុកទៅធ្វើបុណ្យធ្វើទាន់ទៅរកស៊ីទៅប៉ុន្តែញ៉ុមថាញ៉ុមរកតែ១ឆ្នាំ២ឆ្នាំទៀតញ៉ុមអាចទៅនៅផ្ទះធ្វើបុណ្យនៅផ្ទះដែលចាស់ហើយណាស់!!

ក៖ចាំ!!

ខ៖កូនចៅញ៉ុមក៏ធំៗហើយវាធូរធារគ្រប់គ្នាហើយញ៉ុមលែងអីហើយ។

ក៖ចាំ!!ហើយអ៊ីចឹងបើសិនជាអ្នកមីងទៅចៅៗបានអ្នកណាគេមើលវិញទៅអ៊ីចឹង?

ខ៖អត់ដែលមើលចៅណាមីអូន
កូននេះយកទៅដាក់សាលា(ចៅរបស់គាត់)ក៖ហ្ហ៎!!ខ៖ដាក់មួយខែ៥០ សាលាគេមើល។

ក៖ចាំ!

ខ៖កូនចៅទាំងអស់អត់ដែលញ៉ុមអត់ដែលមើលទេអូន ។

ក៖អ៊ិចឹងអ្នកមីងស្រណុកដែរហ្នឹង?

ខ៖ចាំអត់ដែលមើលទេ កូនចៅញ៉ុមតែលើម៉ាក់ប៉ាវា យកកទៅដាក់សាលាកូនញ៉ុម ញ៉ុមមិនដែលមើលចៅទេ វេទនាពិបែរពិបាកអីទេ!! រាល់ថ្ងៃបាយទឹកអីក៏អត់ដែលធ្វើដែរ!!តែមីបងគេហ្នឹងធ្វើហើយយកមកអោយមក ល្ងាចឡើងគេធ្វើឆ្អិនស្មានណាគេយកមកអោយស្មើរហ្នឹងបាយម្ហូបចំនីអីក៏ដោយ។

ក៖ចាំ!!អ៊ីចឹងជីវិតអ្នកមីងសមប្រកបដែរ!!

ខ៖ចាំហ្នឹងហើយ។

ក៖អ៊ីចឹងបើប្តីអត់មានស្រីមួយទៀតថាស្រួលម៉ង!!

ខះចាំ!!ស្រួលម៉ង!!ប៉ុន្តែថាឥឡូវអើរវាផុតហើយអូនណាស់!!

កះចាំ!!

ខះវាអានេះវានិស្ស័យរបស់យើងទេ យើងថាអញ្ចឹងទៅ។

កះចាំហ្នឹងហើយ។អ៊ិចឹងអ្នកមីងសំរាប់ជីវិតរបស់អ្នកមីង
សំរាប់មួយនេះគឺជាសំនួរមួយចុងក្រោយហាអ្នកមីងហាំ!!

ខះចាំ!!

កះមីងមានអីនិយាយបន្ថែមទៀតអ្នកមីងអាចនិយាយចេញពីបេះដូងដើម្បីទុកអោយកូនចៅអ្នកមីងស្តាប់អ៊ិចឹងហាំ!!អ៊ីចឹងតើមីងមានបទពិសោធន៍អីខ្លះដែលល្អនៅក្នុងជីវិតក៏ដូចជាប្រៀនប្រដៅកូនអ៊ិចឹងហា ចង់ប្រៀបប្រដៅកូនចៅអ្នកមីងម៉េចដែរ?

ខះប្រៀនប្រដៅកូនញ៉ុមអោយខំរកស៊ី
កុំអោយលំបាកវេទនាអ៊ិចឹងអូនគេធ្វើបុណ្យធ្វើទានញាតិជិតខាងតែប៉ុណ្ណឹងអូន!!

កះចាំ!!

ខះហ្នឹងចិត្តញ៉ុមត្រេកអរកុំអោយកូនមានទុក ទុកឈ្លោះគ្នាអីអីចឹងទៅណាស់
តែប៉ុណ្ណឹង!!ចៅៗ។

កះចាំ!!អ៊ីចឹងអោយពួកគាត់ជៀសផុតពីអីគេដែរមីង?

ខះជៀសផុតកុំអោយមានអាសន្នអត់ក្រអីទៅមុខទៀតអ៊ីចឹតងទៅអូនណាស់។

កះហ៊ីៗ!!

ខះអោយចេះតែរកស៊ីមានបានអ៊ីចឹងទៅ កុំអោយឈ្លោះគ្នា
ចេះធ្វើបុណ្យធ្វើទានទៅអនាគតទៅមុខទៀតទៅយើងវាល្អហើយតែប៉ុណ្ណឹង។

កះចាំអ៊ីចឹងអ្នកមីងមានចង់និយាយបន្ថែមអីទៀតទេ។

ខះប៉ុណ្ណឹងអូនបានហើយ។

ក៖អ៊ីចឹងអរគុណច្រើនសំរាប់ការនិយាយអំពីជីវប្រវត្តិរបស់អ្នកមីងអ៊ីចឹងហាំ!!កូនចៅអ្នកមីងគាត់នឹងបានស្តាប់ហាំ!!

ខ៖ចាំ!!

ក៖ហើយគាត់នឹងដឹងថាសំលេងអ្នកមីងយ៉ាងម៉េចៗ!!

ខ៖ចាំ!!

ក៖អ៊ិចឹងអរគុណច្រើនអ្នកមីង!!